01346607

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 08 / 11 / 2016
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ឯកសារ E445/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**សាធារណៈ / Public**

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**ជូនចំពោះ÷** ភាគីទាំងអស់ក្នុងសំណុំរឿង ០០២

**ពី÷** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន÷** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ÷** សេចក្តីសម្រេចលើសំណើសុំរបស់មេធាវីការពារក្តី នួន ជា អនុលោមតាមវិធាន ៨៧(៤) និង វិធាន ៩៣ នៃវិធានផ្ទៃក្នុង (E445/1)

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើជាឯកសារសម្ងាត់មួយដែលមេធាវីការពារក្តី នួន ជា បានដាក់នៅថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦ អនុលោមតាមវិធាន ៨៧(៣) វិធាន ៨៧(៤) និង វិធាន ៩៣ នៃវិធានផ្ទៃក្នុង សុំឱ្យទទួលយកឯកសារចំនួន ៨ និង បើកកិច្ចស៊ើបសួរពាក់ព័ន្ធនឹងឯកសារចំនួនពីរ។ មេធាវីការពារក្តី នួន ជា សន្និដ្ឋានថា ពួកគេអាចប្រើប្រាស់ឯកសារដូចបានស្នើសុំទាំងនេះដើម្បីតាំងសំណួរទៅកាន់ Stephen MORRIS (2-TCE-98) (ឯកសារ E445/1)។ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សេចក្តីសន្និដ្ឋានផ្ទាល់មាត់ឆ្លើយតបទៅនឹងសំណើសុំនេះនៅថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦ (ប្រតិចារិកសវនាការ ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦ ទំព័រ ៧៣-៨៣ សេចក្តីព្រាង)។

២. នៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៦ នៅមុនពេលផ្តល់សក្ខីកម្មរបស់ 2-TCE-98 អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចផ្ទាល់មាត់មួយដោយក្នុងនោះ អង្គជំនុំជម្រះបានទទួលយកឯកសារពីលេខរៀងទី ១ ដល់លេខរៀងទី ៧ ដូចបានលើកឡើងនៅក្នុងឯកសារ E445/1

ហើយបានច្រានចោលឯកសារលេខរៀងទី ៨ ព្រមទាំងបានប្រកាសជាអសារបង់នូវសំណើសុំពាក់ព័ន្ធនៅក្នុងចម្លើយតបដែលត្រូវបានធ្វើឡើងដោយសហព្រះរាជអាជ្ញាដែលសុំឱ្យទទួលយកឯកសារចំនួនបី។ ចំពោះឯកសារលេខរៀងទី១ អង្គជំនុំជម្រះបានបង្គាប់ឱ្យមេធាវីការពារក្ដី នួន ជា បង្ហាញផ្នែកនៃឯកសារចំនួន ២១៥ ទំព័រ ដែលពាក់ព័ន្ធបំផុតទៅនឹងសក្ខីកម្មរបស់ 2-TCE-98 ហើយដែលមេធាវីការពារក្ដីមានបំណងប្រើប្រាស់។ ក្រោយពេលពិនិត្យមើលសំណើសុំអនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុងរួចមក អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា ខ្លួនបានស្នើសុំឱ្យអង្គភាពគាំពារសាក្សី និង អ្នកជំនាញ ទាក់ទងអ្នកជំនាញខាងលើឱ្យផ្ដល់សំណៅនៃឯកសារលេខរៀងទី១ទាំងស្រុង។ អង្គជំនុំជម្រះបានច្រានចោលសំណើសុំអនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុងពាក់ព័ន្ធនឹងឯកសារលេខរៀងទី២ (ប្រតិចារឹកសវនាការ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៦ ទំព័រ ៥១-៥២ សេចក្ដីព្រាង)។ ហេតុដូច្នេះ អង្គជំនុំជម្រះសូមផ្ដល់សំអាងហេតុនៃសេចក្ដីសម្រេចនេះ។

៣. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង នៅគ្រប់ដំណាក់កាលនៃនីតិវិធីទាំងអស់ អង្គជំនុំជម្រះអាចទទួលយកនូវភស្តុតាងទាំងឡាយណា ដែលអង្គជំនុំជម្រះយល់ឃើញថាមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត នៅពេលដែលភស្តុតាងនោះក៏បំពេញផងដែរនូវបទដ្ឋាន*ការបញ្ជាក់បឋម* នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាព ដែលតម្រូវដោយវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះនឹងសម្រេចលើសំណើសុំឱ្យទទួលយកភស្តុតាងថ្មី ស្របតាមលក្ខណៈវិនិច្ឆ័យដូចមានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ក៏តម្រូវផងដែរថា ភាគីដែលស្នើសុំឱ្យទទួលយកភស្តុតាងថ្មីត្រូវបញ្ជាក់ពីមូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ ភាគីដែលស្នើសុំត្រូវធ្វើឱ្យអង្គជំនុំ-ជម្រះសាលាដំបូងជឿជាក់ថា ភស្តុតាងដែលខ្លួនបានស្នើសុំដាក់នោះ មិនអាចរកបាននៅមុនពេលចាប់ផ្ដើមការជំនុំជម្រះ ឬ មិនអាចត្រូវបានរកឃើញ ទោះបីជាបានយកចិត្តទុកដាក់សម-ស្របហើយក៏ដោយ។ ទោះបីជាយ៉ាងណា នៅក្នុងករណីមួយចំនួន អង្គជំនុំជម្រះសាលាដំបូងបានទទួលយកភស្តុតាងនានាដែលពុំបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យនេះឡើយ រួមទាំងក្នុងករណីដែលភស្តុតាងពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងសម្ភារៈដែលមានរួចហើយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និង ក្នុងករណីដែលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យមានការវាយតម្លៃប្រភពទាំងនេះរួមគ្នា និង ករណីដែលឯកសារដែលបានស្នើសុំនេះ គឺជាភស្តុតាងដោះបន្ទុក

ដែលតម្រូវឱ្យមានការវាយតម្លៃ ដើម្បីជៀសវាងកំហុសក្នុងការស្វែងរកយុត្តិធម៌ (*សូមមើល* ឯកសារ E319/36/2)។

៤. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា សំណើសុំនេះត្រូវបានដាក់តាមកាលបរិច្ឆេទដែលត្រូវបានកំណត់ដោយអង្គជំនុំជម្រះត្រឹមថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦ (មើលអ៊ីម៉ែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់ ផ្ញើជូនភាគីកាលពីថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦) ដើម្បីដាក់សេចក្តីសន្និដ្ឋានលើសំណើសុំតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងសក្ខីកម្មរបស់ 2-TCE-98។ ហេតុដូច្នេះ សំណើសុំនេះបានដាក់ទាន់ពេលវេលា។

៥. ឯកសារលេខរៀងទី១ ដល់លេខរៀង ទី៧ រួមមានសម្ភារៈដែលបាននិពន្ធដោយ ឬ ដែលពិភាក្សាអំពីស្នាដៃនិពន្ធ និង ការស្រាវជ្រាវរបស់ 2-TCE-98។ អង្គជំនុំជម្រះយល់ឃើញថា ឯកសារទាំងនេះមានការពាក់ព័ន្ធនឹងចំណេះដឹង និង ជំនាញរបស់របស់អ្នកជំនាញ ហើយនឹងទាក់ទងយ៉ាងជិតស្និទ្ធនឹងសក្ខីកម្មដែលរំពឹងនឹងថាទទួលបានពីគាត់។ ឯកសារខ្លះក៏អាចត្រូវបានប្រើប្រាស់នៅក្នុងអំឡុងពេលនៃការសួរសំណួរទៅកាន់អ្នកជំនាញ ហើយអាចពាក់ព័ន្ធសម្រាប់ការវាយតម្លៃលើភាពអាចជឿជាក់បានលើអ្នកជំនាញ។ ឯកសារលេខរៀងទី៨ គឺជាកម្រងលិខិតដែលសម្តេចព្រះបរមរតនកោដ្ឋនរោត្តមសីហនុបានបញ្ជូនទៅកាន់នាយករដ្ឋមន្ត្រីវៀតណាម នៅខែ តុលា និងខែ វិច្ឆិកា ឆ្នាំ ១៩៧៩។ អង្គជំនុំជម្រះកត់សម្គាល់ ឃើញថា កាលពីលើកមុន អង្គជំនុំជម្រះបានច្រានចោលការសុំឱ្យទទួលយកលិខិតទាំងនេះដោយសារហេតុផលផ្សេងៗគ្នា (ឯកសារ E396/4)។ នៅក្នុងករណីនេះ អង្គជំនុំជម្រះកត់សម្គាល់ឃើញថាឯកសារលេខរៀងទី៨ គឺជាឯកសារច្រំដែលជាមួយនឹងភស្តុតាងផ្សេងទៀតនៅក្នុងសំណុំរឿង។ ហេតុដូច្នេះ អង្គជំនុំជម្រះច្រានចោលការស្នើសុំឱ្យទទួលយកឯកសារនេះ។

៦. នាពេលនេះ អង្គជំនុំជម្រះសូមងាកមកពិចារណាលើសំណើសុំចំនួនពីរអនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង។ ក្រោយពីបានពិនិត្យសំណើសុំទីមួយអនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុងរួចមក អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ឯកសារមួយដែលបានស្នើសុំគឺជាសំណៅនៃឯកសារលេខរៀងទី១ ទាំងស្រុង ពោលគឺនិក្ខេបបទថ្នាក់បណ្ឌិតរបស់អ្នកជំនាញដែលអង្គជំនុំជម្រះបានសម្រេចទទួលយកអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះស្នើសុំឱ្យអង្គភាពគាំពារសាក្សី និង អ្នកជំនាញ ទាក់ទង 2-TCE-98 ឱ្យផ្តល់សំណៅឯកសារលេខរៀងទី១ ទាំងស្រុង។ អង្គជំនុំជម្រះយល់ឃើញថា ការធ្វើដូច្នេះ

នឹងបំពេញតាមសំណើសុំរបស់មេធាវីការពារក្តី នួន ជា ហើយមិនចាំបាច់បើកការស៊ើបសួរបន្ថែមអនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុងនៅក្នុងករណីនេះទេ។ សំណើសុំទីពីរអនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុងពាក់ព័ន្ធនឹងសក្ខីកម្មរបស់អ្នកជំនាញនៅក្នុងឆ្នាំ ១៩៩១ នៅចំពោះមុខអនុគណកម្មាធិការនៃសភាជាតិសហរដ្ឋអាមេរិក។ អង្គជំនុំជម្រះយល់ឃើញថា វាពុំចាំបាច់ ឬពុំសមស្របក្នុងការបង្គាប់ឱ្យធ្វើការស៊ើបអង្កេតបន្ថែមនៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីចុងក្រោយនេះហើយ ជាពិសេស ដោយហេតុថា ឯកសារនេះហាក់ដូចជាមិនងាយអាចរកបាន ឬនៅមិនទាន់អាចរកបាននៅឡើយទេ។ លើសពីនេះ មេធាវីការពារក្តី នួន ជា មានឱកាសក្នុងការសួរសំណួរទៅកាន់ 2-TCE-98 ដោយផ្ទាល់អំពីខ្លឹមសារនៃសក្ខីកម្មរបស់គាត់។

៧. តាមសំអាងហេតុខាងលើ និង អនុលោតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងទទួលយកឯកសារលេខរៀងទី១ ដល់ទី៧ ដូចបានលើកឡើងនៅក្នុងឯកសារ E445/1 និង ច្រានចោលការស្នើសុំឱ្យទទួលយកឯកសារលេខរៀងទី៨។ ចំពោះឯកសារលេខរៀងទី១ ដល់ទី៧ អង្គជំនុំជម្រះដាក់លេខសម្គាល់ E3/10699, E3/10700, E3/10701, E3/10702, E3/10703, E3/10704, E3/10705។ ដោយហេតុថា អង្គជំនុំជម្រះច្រានចោលការស្នើសុំឱ្យទទួលយកឯកសារលេខរៀងទី៨ ហេតុដូច្នេះ សំណើសុំនៅក្នុងចម្លើយតបដែលត្រូវបានធ្វើឡើងដោយសហព្រះរាជអាជ្ញាសុំឱ្យទទួលយកឯកសារចំនួនបី ត្រូវបានចាត់ទុកជាអសារបង់។ ក្រោយពីពិចារណាលើសំណើសុំអនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង អង្គ-ជំនុំជម្រះស្នើសុំឱ្យអង្គភាពគាំពារសាក្សី និង អ្នកជំនាញ ទាក់ទងទៅអ្នកជំនាញរូបនេះឱ្យផ្តល់សំណៅទាំងស្រុងនៃឯកសារលេខរៀងទី១ ដែលបានស្នើសុំ។ អង្គជំនុំជម្រះច្រានចោលសំណើសុំអនុលោតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុងចំពោះឯកសារទី ២ ដែលបានស្នើសុំ។

៨. អនុស្សរណៈនេះគឺជាការឆ្លើយតបផ្លូវការរបស់អង្គជំនុំជម្រះចំពោះឯកសារ E445/1។